**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
**ក្រសួងមហាផ្ទៃ**
លេខ : ០៧៨ សព្រក

## សេចក្តីប្រកាសព័ត៌មាន
## ស្តីពី ផលប៉ះពាល់តំបន់ និងជនស៊ីវិលកម្ពុជា ដោយអំពើឈ្លានពានរបស់ភាគីថៃ លើដែនអធិបតេយ្យកម្ពុជា ពីម៉ោង៦ល្ងាច ថ្ងៃទី២៥ ខែធ្នូ ដល់ម៉ោង៧ព្រឹក ថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២៥

គិតចាប់ពីម៉ោង៦ល្ងាច ថ្ងៃទី២៥ ខែធ្នូ រហូតដល់ម៉ោង៧ព្រឹក ថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២៥នេះ អំពើឈ្លានពានរបស់រដ្ឋាភិបាល និងយោធាថៃ ជាពិសេសការផ្លោង និងទម្លាក់គ្រាប់គ្រប់ប្រភេទ គ្រប់ទម្រង់ ចូលតំបន់ស៊ីវិល បានបណ្តាលឱ្យមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដូចខាងក្រោម៖

**១-ករណីពលរដ្ឋស្លាប់ និងរបួសថ្មី៖** គ្មាន។ គិតសរុបពីថ្ងៃទី៧ ខែធ្នូ មកដល់ពេលនេះ មានពលរដ្ឋស្លាប់ចំនួន ៣០នាក់ និងរបួសចំនួន៨៨នាក់។

**២-ករណីពលរដ្ឋនៅជំរំភៀសសឹក៖** គិតសរុបពីថ្ងៃទី៧ ខែធ្នូមក មានជនភៀសសឹកសរុប **៦៤៤.៤៤២នាក់** ក្នុងនោះស្ត្រី ៣៣៦.២៤០នាក់ និងកុមារ២០៤.៩៩២នាក់។ តួលេខនេះ អាចមានការប្រែប្រួលជាបន្តបន្ទាប់ទៀត។

**៣-ករណីបំផ្លិចបំផ្លាញហេដ្ឋារចនាសម្ព័ន្ធរូបវន្តស៊ីវិលថ្មី៖ ខូចខាតផ្ទះ៣ខ្នង និងអគាររដ្ឋ១** នៅខេត្តបាត់ដំបង។ គិតសរុបពីថ្ងៃទី៧ ខែធ្នូមក **ការខូចខាតទ្រព្យសម្បត្តិឯកជន** រួមមាន ផ្ទះពលរដ្ឋ១៤៥ខ្នង អគារឯកជន៦ អគារស្នាក់នៅ/សណ្ឋាគារ៥ ស្ថានីយ៍ប្រេង១ រថយន្ត២៧គ្រឿង ម៉ូតូ១គ្រឿង លានទិញដំឡូង១ អគារឃ្លាំងទំនិញ១ បង្គោលអង់តែនទូរសព្ទ២។ **ការខូចខាតទ្រព្យសម្បត្តិសាធារណៈ** រួមមាន សាលារៀន៦ មណ្ឌលសុខភាព២ សំណង់អគារ១៤ វត្តអារាម៥ សាលាឆទាន១ រថយន្ត១គ្រឿង ប្រាសាទបុរាណមួយចំនួន ស្ពាន៥ ផ្សារ១ និងផ្លូវចំនួន៣។ មកដល់ពេលនេះ មានប្រជាជនកម្ពុជាជាងកន្លះលាននាក់ រួមមានស្ត្រីជាង៥០% និងកុមារជាង៣០% កំពុងរងទុក្ខ បន្ទាប់ពីបង្ខំចិត្តភៀសសឹក គេចគ្រាប់កាំភ្លើង គ្រាប់ផ្លោងតូចធំ និងគ្រាប់ទម្លាក់ពីយន្តហោះ ដែលបំផ្លាញផ្ទះសំបែង សាលារៀន និងភូមិករពួកគាត់ជាបន្តបន្ទាប់រួចទៅហើយ។ ជាក់ស្តែង មកដល់ព្រឹកថ្ងៃទី២៦ ខែធ្នូនេះ របាយការណ៍បឋមបានបញ្ជាក់ថា មានពលរដ្ឋស៊ីវិលរងរបួសបន្ថែមទៀតនៅសង្កាត់ផ្សារកណ្តាល ក្រុងប៉ោយប៉ែត ដោយសារអំបែងគ្រាប់ផ្លោងថៃ។

ក្នុងគោលដៅស្វះស្វែងរកសន្តិភាពស្របតាមគោលជំហរតាំងពីដើមមក **ក្រសួងមហាផ្ទៃ នៃរាជរដ្ឋាភិបាលកម្ពុជា** គាំទ្រពេញទំហឹងលើខ្លឹមសារជំនួបសន្ទនាតាមទូរសព្ទ រវាង **សម្តេចធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃកម្ពុជា និង **ឯកឧត្តម Marco Rubio** រដ្ឋមន្ត្រីការបរទេសអាម៉េរិក កាលពីយប់ថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០២៥ ដែលក្នុងជំនួបនោះ **ឯកឧត្តមប្រមុខការទូត** បានគូសបញ្ជាក់ពីគោលជំហរសហរដ្ឋអាម៉េរិកចង់ឃើញសន្តិភាព ស្ថិរភាព និងខិតខំជំរុញឱ្យមានបទឈប់បាញ់ឆាប់រហ័ស ខណៈ **សម្តេចធិបតី** បានបញ្ជាក់ជាថ្មីអំពីការប្រកាន់ខ្ជាប់យ៉ាងម៉ឺងម៉ាត់របស់កម្ពុជា បន្តអនុវត្តតាមស្មារតីសេចក្តីថ្លែងការណ៍រួមទីក្រុងគូឡាឡាំពួ និងសង្ឃឹមថា ភាគីទាំងពីរនឹងបន្តធ្វើការជាមួយគ្នាស្របតាមកិច្ចព្រមព្រៀងមានស្រាប់។

ថ្ងៃនេះ ជាថ្ងៃទី២០ហើយ ដែលរដ្ឋាភិបាល និងយោធាថៃ ឈ្លានពានដែនអធិបតេយ្យកម្ពុជា និងប្រព្រឹត្តបទឧក្រិដ្ឋខុសពីច្បាប់អន្តរជាតិ។ ២០ថ្ងៃនេះ កម្លាំងកងយោធពលខេមរភូមិន្ទ និងនគរបាលការពារព្រំដែន ក្រោមយុទ្ធសាស្ត្រការពារជាតិ **សម្តេចតេជោ ហ៊ុន សែន** និង**សម្តេចធិបតី ហ៊ុន ម៉ាណែត** បានតស៊ូប្រយុទ្ធការពារបូរណភាពទឹកដី និងអធិបតេយ្យភាពជាតិប្រកបដោយភាពអង់អាចជាញជ័យ ទន្ទឹមគ្នានឹងកម្លាំងមហាសាមគ្គីជាតិខ្មែរក៏កាន់តែរឹងមាំខ្ពស់ត្រដែត ដោយកូនខ្មែរគ្រប់រូប នៅគ្រប់ទីកន្លែងបានវេញស្មារតីរួបរួមជាធ្លុងមួយកាន់តែខ្លាំងក្លា ជឿជាក់ និងផ្តល់ថាមពលគាំទ្រមហិមាជូនថ្នាក់ដឹកនាំ និងយុទ្ធជនជួរមុខ ព្រមទាំងរួមចំណែកសម្រាលបន្ទុកការលំបាករបស់ពលរដ្ឋភៀសសឹក។ ក្រសួងមហាផ្ទៃ មានមោទនភាព សូមកត់ត្រាទុកនូវបេតិកភ័ណ្ឌប្រវត្តិសាស្ត្រមួយនេះ និងសូមអំពាវនាវឱ្យកូនខ្មែរបន្តថែរក្សាវប្បធម៌មួយនេះឱ្យបានឋិតថេរជានិរន្តរ៍៕

ថ្ងៃសុក្រ ៧កើត ខែបុស្ស ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២៥